# កម្មវិធីវិធានការចំរុះ ថែទាំដំណាំ (IPM) ជាតិកម្ពុជា

ម.ឯ.ស.គស៊ីកម្ម
ASDC
ថ្ងៃទី..........
លេខ..........
អំណោយ..........





# តើ IPM ជាអ្វី?

## IPM =វិធានការចំរុះថែទាំដំណាំ ឬ ភាពវ័យឆ្លាតក្នុងការគ្រប់គ្រងដំណាំ

ម.ព.ឯ.ក AIDOC
Code: 248-014
Date:
Donated by:

វិធានការចំរុះថែទាំដំណាំឬ IPM គឺជាការរួមបញ្ចូលគ្នា នូវរាល់យុទ្ធសាស្រ្ត ទាំងឡាយណាដែល កសិករបានប្រើប្រាស់ក្នុងការថែទាំដំណាំឲ្យលូតលាស់ល្អ និងកាត់បន្ថយការបំផ្លាញរបស់កត្តាចង្រៃ ដូចជា សត្វល្អិត កណ្តុរ ស្មៅចង្រៃ និងជំងឺ ។ យុទ្ធសាស្រ្តដែលកសិករយកចិត្តទុកដាក់ គឺសំដៅដល់ការធ្វើអោយមាននិរន្តភាពផលិតកម្ម តាមរយៈការថែរក្សាជីវសាស្រ្តចំរុះ នៃធម្មជាតិនៅក្នុងវាលស្រែ ។ វគ្គបណ្តុះបណ្តាល IPM បានបង្កើតចំណេះដឹងដល់កសិករអំពីសមាសភាពទាំងអស់នៃប្រព័ន្ធបរិស្ថានដំណាំ និងការគ្រប់គ្រងរបស់វា ។ ការអនុវត្តន៍ IPM បានផ្តល់នូវនិរន្តភាព ៣ គឺៈ និរន្តភាពផលិតកម្មកសិកម្ម សេដ្ឋកិច្ចសង្គម និងបរិស្ថាន ។

## IPM គឺជាអ្វីៗដែលកសិករ អនុវត្តនៅក្នុងស្រែ



**នាយកដ្ឋានក្សេត្រសាស្រ្ត នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នសំរបសំរួលកម្មវិធី IPM ជាតិ សំរាប់បណ្តុះបណ្តាលកសិករ ។**

ម.ឯ.ទ.កសិកម្ម
ASDC
ថ្ងៃទី.......................
លេខ.........................
អំណោយ....................

កសិករជាគ្រូ IPM ក្នុងវគ្គបំពាក់បំប៉ន នៅខេត្តកណ្តាល



# ហេតុអ្វីបានជាមាន IPM ?

## បញ្ហាជាច្រើនបានកើតមានឡើងជាមួយនឹងបដិវត្តន៍បៃតង

ដំណាំស្រូវនៃតំបន់ អាស៊ី ភាគអគ្នេយ៍ បានវិវឌ្ឍន៍ ជាច្រើនពាន់ឆ្នាំមកហើយ ដែលមានប្រព័ន្ធបរិស្ថានចំរុះសំបូរបែបបំផុតនៅក្នុងវិស័យកសិកម្ម។ "បដិវត្តន៍បៃតង" នាំមកនូវការផ្លាស់ប្តូរ សមាសភាពនៅក្នុងប្រព័ន្ធនេះ នាទសវត្សឆ្នាំ ១៩៦០ និងឆ្នាំ ១៩៧០ តាមរយៈការបង្កើតនូវ ពូជស្រូវ "ទំនើប" ដែលជំរុញអោយមានការប្រើប្រាស់ ថ្នាំពុលកសិកម្ម និងជីគីមី កាន់តែច្រើនឡើងៗ ។ ការប្រើប្រាស់ថ្នាំពុលគីមីទាំងនេះ បានក្លាយទៅជាវិធីសាស្ត្រ តែមួយគត់ នៅក្នុងការកំចាត់កត្តាចង្រៃ ដែលបានគ្របដណ្តប់ លើតំបន់ជាច្រើនក្នុងពិភពលោក ។

បញ្ហាជាច្រើននៅតែបន្តកើតមានឡើង ។ គេបានរកឃើញថា ការដាំស្រូវពឹងផ្អែកលើថ្នាំពុលកសិកម្ម បានគំរាមកំហែងយ៉ាងខ្លាំងដល់សុវត្ថិភាពស្បៀង និងបង្កើតឱ្យមានគ្រោះថ្នាក់ដល់ប្រព័ន្ធបរិស្ថានដំណាំ ។

បន្ទាប់មកអ្នកវិទ្យាសាស្ត្រទាំងឡាយបានរកឃើញថា ការប្រើប្រាស់ថ្នាំពុលខុសបច្ចេកទេស បានបំផ្លាញបណ្តាញចំណីអាហារធម្មជាតិ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក គ្រប់សរីរាង្គទាំងអស់នៅក្នុងវាលស្រែ ។

### សេចក្តីត្រូវការ IPM នៅប្រទេសកម្ពុជា

* ប្រទេសកម្ពុជា ដែលមានអត្រាកំណើនប្រជាជនប្រមាណ ៣% ក្នុងមួយឆ្នាំ (១៩៩០-១៩៩៥) បាននិងកំពុងពឹងផ្អែកទៅលើការបង្កើនផលិតកម្មដំណាំស្រូវ ដើម្បីធានានូវសុវត្ថិភាពស្បៀង ។

* ដូចបណ្តាប្រទេសនៅអាស៊ីដទៃទៀតដែរ ប្រទេសកម្ពុជាបានក្រឡេកមើលមេរៀនពីបដិវត្តន៍បៃតង ដើម្បីផ្តល់នូវចំលើយសំរាប់ការអភិវឌ្ឍន៍ ។

* ការយកចិត្តទុកដាក់ទៅលើការកែលំអកសិកម្មអតិផល និងការប្រើប្រាស់ពូជដែលផ្តល់ទិន្នផលខ្ពស់ ។

នៅក្នុងន័យនេះ កសិករកម្ពុជាបានរកឃើញដោយខ្លួនឯងថា ពួកគេបានជួបប្រទះជាមួយនឹងការជ្រើសរើសថ្មី និងការធ្វើសេចក្តីសំរេចចិត្ត ។ ជាទូទៅ រាល់ការសំរេចចិត្តនានា អំពីការដាំដុះដំណាំស្រូវ តែងតែមានឥទ្ធិពលទៅលើការរាតត្បាត របស់សត្វចង្រៃ ស្មៅ និងជំងឺ ។

ដូច្នេះកសិករត្រូវមានចំណេះដឹងក្នុងការធ្វើសេចក្តីសំរេចចិត្ត ដូចជា :

- តើត្រូវបាចជីនៅពេលណា ចំពោះពូជថ្មី ?
- តើជីប្រភេទណាខ្លះ ដែលអាចលាយគ្នាដើម្បីប្រើប្រាស់បានល្អ ?
- តើត្រូវព្រោះ ឬស្ទូង យ៉ាងដូចម្តេច ? ប្រើពូជប៉ុន្មាន ?
- តើគ្រប់គ្រងទឹក យ៉ាងដូចម្តេច ?
- តើសត្វចង្រៃមានឥទ្ធិពលដូចម្តេច ទៅលើទិន្នផល ?
- តើថ្នាំពុលគីមីមានឥទ្ធិពលយ៉ាងណាខ្លះ ទៅលើទិន្នផល សុខភាព និងបរិស្ថាន ?

ការកំចាត់កត្តាចង្រៃ ដោយប្រើថ្នាំគីមីខុសបែបបទបច្ចេកទេស បានជះឥទ្ធិពលយ៉ាងអាក្រក់ដល់ តំលៃផលិតកម្ម សុខមាលភាពមនុស្ស និងបរិស្ថាន រួមទាំងពាណិជ្ជកម្មអន្តរជាតិ ផងដែរ ។

បញ្ហាថ្មីៗ ជាច្រើន នៅតែបន្តកើតមានឡើង ។ វិធានការចំរុះថែទាំដំណាំ ឬ IPM គឺជាការជ្រើសរើស ដ៏ប្រសើរបំផុតសំរាប់អនាគត ដោយបានធានានូវសុវត្ថិភាពស្បៀង កាត់បន្ថយការចំណាយក្នុងផលិតកម្ម រក្សាបាននូវបរិស្ថាន សុខភាពមនុស្ស និងចូលរួមចំណែកក្នុងការធ្វើឱ្យមាន និរន្តរភាពក្នុងវិស័យកសិកម្ម ។

តាមរបៀបវារៈ ២១ នៃសន្និសិទរបស់សហប្រជាជាតិស្តីអំពីបរិស្ថាន និងការអភិវឌ្ឍន៍នៅ Rio de Janeiro ឆ្នាំ១៩៩២ ។









សំរាប់ប្រជាជនកម្ពុជា ស្រូវគឺជាម្ហូបអាហារសំខាន់បំផុត ។ គោលដៅជាតិក្នុងការផ្គត់ផ្គង់ស្រូវ ឱ្យបានគ្រប់គ្រាន់ដោយខ្លួនឯង គឺវាមិនមែនគ្រាន់តែជាគោលដៅ សំរាប់សេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ ប៉ុន្តែវាបានបង្ហាញឱ្យឃើញអំពី សារសំខាន់នៃសេដ្ឋកិច្ចសង្គមក្នុងផលិតកម្មដំណាំស្រូវដែរ ។

តាមឯកសារស្តីពីសុវត្ថិភាពស្បៀង ក្នុងសន្និសីទស្បៀងអាហារពិភពលោក ដែលបានរៀបចំដោយអង្គការ FAO នៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី នៅឆ្នាំ ១៩៩៦ ។

តាមរយៈការសិក្សាស្រាវជ្រាវនៅប្រទេសកម្ពុជា ដោយអង្គការ IRRI FAO និងកម្មវិធី IPM ជាតិ បានបង្ហាញថា :

*កសិករតិចតួចណាស់ ដែលស្គាល់សត្វមានប្រយោជន៍ (ប្រេដាទ័រ ប៉ារ៉ាស៊ីត) ។
*ការប្រើប្រាស់ខុស និងយល់ច្រឡំពីថ្នាំពុល បាននិងកំពុងកើតមានរាលដាល ។
*កសិករមានកង្វះខាតចំណេះដឹង អំពីការគ្រប់គ្រងទឹក និងដី ការធ្វើសេចក្តីសំរេចចិត្តកំចាត់កត្តាចង្រៃ និងទិន្នផល ។
*កសិករហាក់បីដូចជាមានជំនឿថា ការដាំដុះស្រូវពូជទំនើប ត្រូវពឹងផ្អែកទៅលើវិធីសាស្ត្រ និងបច្ចេកទេសខ្ពស់ ដោយរួមបញ្ចូលទាំងថ្នាំសំលាប់សត្វល្អិតផង ។

ដោយសារការខ្វះខាតចំណេះដឹង អំពីប្រព័ន្ធបរិស្ថានដំណាំស្រូវ កសិករ និងអ្នកផ្សព្វផ្សាយតែងតែចាត់វិធានការ ទប់ទល់នឹងរោគសញ្ញានានា ដោយមិនបានស្វែងយល់ពីមូលហេតុដែលនាំឱ្យមានបញ្ហា ។

## ប្រសិទ្ធិភាព IPM នៅកម្ពុជា

លទ្ធផលនៃការអនុវត្តន៍ IPM នៅប្រទេសកម្ពុជា បានបង្ហាញថា កសិករដែលបានរៀន IPM អាចដាំដំណាំ អោយដុះលូតលាស់ល្អ ដោយកាត់បន្ថយបញ្ហាកត្តាចង្រៃនានា នៅក្នុងស្រែតាមរយៈ ការគ្រប់គ្រងដំណាំបានល្អ និងធ្វើសេចក្តីសំរេចចិត្តបានត្រឹមត្រូវ ដោយផ្អែកទៅលើការវិភាគប្រព័ន្ធបរិស្ថានដំណាំស្រូវ ។ កសិករ IPM បានក្លាយទៅជាអ្នកគ្រប់គ្រង ដែលមានទេពកោសល្យយ៉ាងល្អ។ ពួកគេបានកាត់បន្ថយការប្រើប្រាស់សារធាតុគីមី បង្កើនប្រាក់ចំណេញ បង្កើនទិន្នផល រក្សាបាននូវសុខមាលភាព និងបរិស្ថាន ។ តាមតួលេខនៅឆ្នាំ ១៩៩៦ បានបង្ហាញថា កសិករដែលរៀន IPM ចប់ បានបង្កើនទិន្នផលស្រូវ ២០% និងអត្រាប្រាក់ចំណេញរហូតដល់ ៣៣% ។

## កម្មវិធី IPM បណ្តុះបណ្តាលកសិករជាតិកម្ពុជា

ដោយសង្កេតឃើញអត្ថប្រយោជន៍នៃការងារ IPM ដែលអាចឈានទៅបង្កើតបានជាសហគមន៍កសិកម្ម ទើបក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតឡើងនូវកម្មវិធី IPM បណ្តុះបណ្តាលកសិករជាតិកម្ពុជា ។

កម្មវិធីនេះ បានចាប់ផ្តើមនៅឆ្នាំ ១៩៩៣ ដោយនៅពេលនោះ ប្រទេសកម្ពុជាបានចូលរួមជាសមាជិកនៃកម្មវិធីអន្តរប្រទេស របស់អង្គការ FAO សំរាប់ IPM លើដំណាំស្រូវនៅតំបន់ អាស៊ីភាគអគ្នេយ៍ និងអាស៊ីខាងត្បូង ដែលមានប្រទេសចំនួន ១៣ ជាសមាជិក ។ សកម្មភាព IPM បានដំណើរការពីពេលនោះមក ក្រោមការជួយឧបត្ថម្ភពីអង្គការ FAO, IRRI និងIDRC ។ នៅឆ្នាំ ១៩៩៧ ប្រទេសកម្ពុជាបានចូលជាសមាជិកនៃកម្មវិធី IPM ដំណាំបន្លែរបស់អង្គការ FAO ប្រចាំតំបន់អាស៊ីភាគអគ្នេយ៍ ។

នៅឆ្នាំ ១៩៩៧ មានគ្រូបង្គោល ដែលធ្វើការជាមួយកសិករនៅ : ខេត្តបាត់ដំបង បន្ទាយមានជ័យ កណ្តាល កំពង់ស្ពឺ កំពង់ចាម ព្រៃវែង ពោធិ៍សាត់ រតនគិរី សៀមរាប ស្វាយរៀង និងតាកែវ ។

ស្រូវ និងបន្លែ គឺជាដំណាំសំខាន់ សំរាប់ទិសដៅនៃការងារ IPM កម្ពុជា នៅថ្ងៃមុខ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដំណាំផ្សេងទៀត ដូចជា ដំណាំឈើហូបផ្លែ ក៏នឹងត្រូវបញ្ចូលនៅក្នុងកម្មវិធីផងដែរ ។

កម្មវិធីបណ្តុះបណ្តាលនេះ ប្រើប្រាស់វិធីសាស្ត្រសាមញ្ញ ដោយមានការចូលរួម ពីកសិករគ្រប់សកម្មភាពសិក្សា រួមទាំងធ្វើពិសោធន៍ផ្ទាល់នៅក្នុងស្រែ ។

" ស្រែ គឺជា សៀវភៅ សំរាប់សិក្សា"






## គោលដៅ

គោលដៅនៃកម្មវិធី IPM ជាតិ គឺសំដៅដល់ការអភិវឌ្ឍន៍នូវ :

***ការបណ្ដុះបណ្ដាលកសិករ ដើម្បីពង្រីកការងារ IPM ឱ្យបានទូទាំងប្រទេស ។**

***ឧបត្ថម្ភគាំទ្រសកម្មភាព IPM នៅតាមបណ្ដាខេត្តនានា ។**

***ក្រុមគ្រូបង្គោលខេត្ត ដែលអាចធ្វើផែនការងារ រៀបចំថវិកា អនុវត្តការងារ គ្រប់គ្រងរដ្ឋបាល និងវាយតំលៃវគ្គបណ្ដុះបណ្ដាលកសិករ ។**

***រៀបចំសហគមន៍ IPM នៅតាមតំបន់ ។**

***ទំនាក់ទំនងរវាងក្រុមកសិករ និងអង្គការអភិវឌ្ឍន៍/ស្រាវជ្រាវ នានា ។**







### កម្មវិធី IPM ជាតិបានលើកកំពស់កសិករអោយ:

.ក្លាយទៅជាអ្នកជំនាញក្នុងការដាំដុះដំណាំ

.ដាំដំណាំឱ្យដុះលូតលាស់ល្អ

.ចុះពិនិត្យស្រែជាប្រចាំ (កសិករចេះស្រឡាញ់ស្រែ)

.ថែរក្សាសត្វមានប្រយោជន៍

.គ្រប់គ្រងការប្រើប្រាស់ទុនផលិតកម្ម យ៉ាងមានប្រសិទ្ធិភាព

## ដំណើរការសិក្សារបស់កសិករ

កម្មវិធី IPM ជាតិកម្ពុជា សហការជាមួយ អង្គការ FAO បានផ្ដោតការយកចិត្តទុកដាក់ទៅលើយុទ្ធសាស្ត្រនៃដំណើរការសិក្សា ដែលមានកសិករចូលរួម ។ សកម្មភាពសិក្សាគឺ :

***ចុះពិនិត្យស្រែមួយសប្ដាហ៍ម្ដង និងធ្វើពិសោធន៍ នៅលើស្រែកសិករផ្ទាល់ពេញមួយវដ្ដជីវិត របស់ដំណាំស្រូវ ។**
***រៀបចំក្រុមពិភាក្សា ដោយខ្លួនឯង ។**
***សាកល្បងអនុវត្តការគ្រប់គ្រងដំណាំផ្សេងៗគ្នា ។**
***កត់ត្រាទិន្នន័យជាប្រចាំ ។**
***ពិភាក្សាលទ្ធផល នៃការសង្កេតនៅក្នុងស្រែ និងកសិករធ្វើសេចក្ដីសន្និដ្ឋាន និងសំរេចចិត្តដោយខ្លួនឯង ។**

ដំណើរការសិក្សា បានផ្ដោតការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រង កត្តាចង្រៃ ។ កសិករបានយល់ដឹងអំពី សក្ដានុពលភាពនៃការបំផ្លាញរបស់ សត្វល្អិតចង្រៃ និងសិក្សាស្វែងយល់ថា តើត្រូវធ្វើដូចម្ដេច ដើម្បីកាត់បន្ថយ ឬជៀសវាង ការបំផ្លាញនេះ ។

កសិករអាចធ្វើពិសោធន៍ អំពីសត្វល្អិតចង្រៃ បានយ៉ាងសាមញ្ញ និងបង្ហាញលទ្ធផលដែលអាចវាស់វែងបានទៅក្នុងរដូវមួយ ។

យុទ្ធសាស្ត្រនេះ អាចលើកទឹកចិត្តដល់កសិករ ក្នុងការដាំដំណាំឱ្យដុះលូតលាស់ល្អ ដែលមានលក្ខណៈធន់ទ្រាំ ទៅនឹងការបំផ្លាញរបស់កត្តាចង្រៃ ដោយមិនពឹងផ្អែកទាំងស្រុងទៅលើការប្រើប្រាស់ថ្នាំពុល ។ កសិករយកចិត្តទុកដាក់ ជាសំខាន់ដល់ចំណេះដឹង និងបទពិសោធន៍ផ្ទាល់របស់ខ្លួន ។ កម្មវិធីក៏បានយកចិត្តទុកដាក់ ដល់ការបង្កើនថាមពលដល់កសិករ តាមរយៈការចូលរួមសិក្សាស្វែងយល់ អំពីប្រព័ន្ធបរិស្ថាននៃដំណាំស្រូវ ។



ស្វាយរៀង



ពោធិសាត់



តាកែវ









## ក្រុមគ្រូ IPM

ក្រុមគ្រូបង្គោល IPM ជាតិ គឺជាអ្នកសំរបសំរួល សកម្មភាពបណ្តុះបណ្តាល IPM ទូទាំងប្រទេស ។ នេះគឺជាក្រុមគ្រូបង្គោល ជំនាញប្រចាំកម្មវិធី នៅនាយកដ្ឋាន ក្សេត្រសាស្ត្រ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ តួនាទីចំបងនៃក្រុមនេះ គឺ :

* រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល IPM
* ផ្តល់បច្ចេកទេស និងឧបត្ថម្ភកម្មវិធីដល់ក្រុមគ្រូ IPM ខេត្ត ។
* ត្រួតពិនិត្យរាល់សកម្មភាព នៃកម្មវិធីទាំងមូល និងរៀបចំរបាយការណ៍សំរាប់អ្នកផ្តល់ជំនួយ និងអ្នកនយោបាយ ។
* រៀបចំកម្មវិធីសិក្សា និងលំហាត់នៅលើវាលស្រែ សំរាប់ការបណ្តុះបណ្តាលកសិករ ។
* ផ្តល់នូវទំនាក់ទំនង ជាមួយភ្នាក់ងារអភិវឌ្ឍន៍ និងស្រាវជ្រាវនានា ។
* រៀបចំ និងអភិវឌ្ឍន៍កម្មវិធីសំរាប់សិក្ខាសាលា IPM ។
* រៀបចំកិច្ចប្រជុំនៅតាមខេត្ត ដូចជាកិច្ចប្រជុំប្រចាំខែ នៃអ្នកសំរបសំរួល IPM ខេត្ត ។
* រៀបចំសិក្ខាសាលាវាយតំលៃការងារ និងលើកគំរោងផែនការការងារ ។
* រៀបចំបើកវគ្គបំពាក់បំប៉ន ពង្រឹងបច្ចេកទេសបន្ថែម ដល់គ្រូបង្គោល IPM ។
* ជំនួយក្នុងការរៀបចំទិវាស្រែ បង្កើតសហគមន៍កសិករ និងការប្រជុំ ឬសមាជកសិករ ។

ក្រុមគ្រូបង្គោល IPM ខេត្ត និងស្រុក ជាអ្នកដំណើរការ សាលារៀនស្រែកសិករ ។ សកម្មភាពនេះ គ្រប់គ្រងដោយអ្នកសំរបសំរួល IPM ប្រចាំខេត្តនីមួយៗ ។

## វគ្គបណ្តុះបណ្តាលគ្រូ (TOT)

គុណភាពនៃគ្រូបង្គោលគឺ មានសារសំខាន់ណាស់សំរាប់កំណត់ ភាពជោគជ័យនៃកម្មវិធី IPM ជាតិ ។ ក្រុមគ្រូបង្គោល IPM ប្រចាំកម្មវិធី បានដំណើរការយ៉ាងសកម្មនូវវគ្គបណ្តុះបណ្តាលគ្រូបង្គោល រយៈពេលវែងនៅលើវាលស្រែផ្ទាល់ សំរាប់អ្នកបច្ចេកទេសកសិកម្ម មកពីមន្ទីរកសិកម្មខេត្ត ឬការិយាល័យស្រុក នានា និងមកពីបណ្តា អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ។ វគ្គនេះមានរយៈពេលពី ១៦_១៨ សប្តាហ៍ អាស្រ័យទៅតាមអាយុដំណាំ ។ វគ្គបានដំណើរការទៅ នៅមជ្ឈមណ្ឌលកសិកម្មនានា នៅតាមបណ្តាខេត្តមួយចំនួន ។ លទ្ធផលចេញពី TOT គឺបង្កើតបានគ្រូបង្គោល IPM សំរាប់បង្រៀនកសិករនៅលើវាលស្រែ ។ ពួកគេបានបញ្ចប់ការសិក្សា ពោរពេញទៅដោយជំនាញ និងបទពិសោធន៍ ។ នៅក្នុងកំឡុងពេលសិក្សា សិក្ខាកាមបាន :

* ទទួលយកនូវការអនុវត្តន៍ យ៉ាងសកម្មរួមផ្សំនឹងការបណ្តុះបណ្តាលផ្នែកទ្រឹស្តីបន្ថែមស្តីពី ការលូតលាស់របស់ដំណាំ ។
* ទទួលនូវការបណ្តុះបណ្តាលពិសេស និងបទពិសោធន៍ អំពីបំរែបំរួលនៃទំនាក់ទំនងរវាងកត្តាចង្រៃ និងពពួកមានប្រយោជន៍នៅក្នុងដំណាំ ។
* ធ្វើស្រែពិសោធន៍ ដើម្បីសិក្សាពីឥទ្ធិពលនៃការស្រាវជ្រាវ ទៅលើការគ្រប់គ្រងកត្តាចង្រៃ ការគ្រប់គ្រងជីជាតិដី ការជ្រើសរើសពូជ ការរៀបចំដី ការគ្រប់គ្រងទឹក និងប្រៀបធៀបទិន្នផល ។
* សិក្សាពីជំងឺ និងប្រព័ន្ធកសិកម្ម ដូចជាការចិញ្ចឹមត្រីក្នុងស្រែ ជាដើម ។
* ទទួលនូវការបណ្តុះបណ្តាល អំពីមេរៀនពិសេសមួយចំនួន ដែលទាក់ទងទៅនឹងកត្តាចង្រៃសំខាន់ៗ និងផលិតកម្មដំណាំនៅក្នុងប្រទេសកម្ពុជា ដូចជាការគ្រប់គ្រងកណ្តុរ ការអភិវឌ្ឍន៍សហគមន៍ បញ្ហាសុខភាពមនុស្ស និងការប្រើប្រាស់ថ្នាំពុល ។
* សិក្សាដោយផ្អែកទៅលើបទពិសោធន៍ដែលមាន និងរបកគំហើញថ្មីៗ តាមវិធីសាស្ត្រ នៃការអប់រំយ៉ាងសាមញ្ញ និងការស្វែងយល់ដោយខ្លួនឯង ។
* បង្រៀនកសិករក្នុងភូមិដែលជាផ្នែកមួយនៃ កម្មវិធីសិក្សាក្នុង TOT ។

នៅពេលបញ្ចប់ការសិក្សានៅ TOT ពួកគេ នឹងរៀបចំបើកសាលារៀន IPM លើស្រែកសិករនៅតាមតំបន់រៀងៗខ្លួន ។







## តំនូសតាងនៃការអភិវឌ្ឍន៍របស់កម្មវិធី IPM ជាតិកម្ពុជា




### សាលារៀនស្រែកសិករ (FFS)

គ្រូបង្គោល IPM ខេត្ត គឺជាអ្នកសំរបសំរួលសាលារៀនស្រែកសិករ ។ សាលារៀនស្រែកសិករជាវេទិកាសេរីដែលអនុញ្ញាតឱ្យ កសិករ និងគ្រូបង្គោលពិភាក្សាគ្នាអំពីគោលការណ៍គ្រឹះ IPM និងការអនុវត្តន៍ការដាំដុះ ការពិសោធន៍ និងការប្រើប្រាស់ចំណេះដឹង ។ សកម្មភាពនេះយកចិត្តទុកដាក់ដល់ការអភិវឌ្ឍន៍ចំណេះដឹង និងជំនាញកសិករ ដើម្បីលើកដំកើង ទាំងមនសិការ និងភាពជឿជាក់របស់កសិករ ។

សាលារៀនស្រែកសិករ គឺជាសាលារៀនសាមញ្ញ និងជាទូទៅ មានកសិករចូលរួមពី ២៥_៣០ នាក់ មកពីភូមិតែមួយ ឬភូមិជិតដែលនៅក្បែរស្រែពិសោធន៍ ។ កសិករទាំងប្រុស និងស្រី ត្រូវបានស្វាគមន៍ឱ្យចូលរួមនៅសាលារៀនស្រែកសិករ ។

គ្រូបង្គោល IPM ចុះទៅសាលារៀនស្រែកសិករ មួយសប្តាហ៍ម្តង ពេញមួយរដូវនៃការលូតលាស់របស់ដំណាំ ក្នុងកំឡុងពេល ១៦_១៨ សប្តាហ៍ អាស្រ័យទៅតាមពូជដំណាំ ។

គ្រូ IPM ជួយកសិករក្នុងការ :

*រៀបចំស្រែពិសោធន៍ និងសកម្មភាពផ្សេងៗ ទៀតឆ្ពោះទៅរក ការសាកល្បងកែលំអ ការយល់ដឹង និងបទពិសោធន៍ ដើម្បីធ្វើយ៉ាងណាដាំដំណាំឱ្យលូតលាស់ ។

*សិក្សាស្រាវជ្រាវអំពីដំណាំដែលពួកគេដាំដុះខ្លួនឯង និងប្រៀបធៀបលទ្ធផលនៃស្រែធ្វើតាមទំលាប់កសិករក្នុងតំបន់ និងស្រែដែលប្រើប្រាស់វិធីសាស្ត្រ IPM ។

*សិក្សាស្វែងយល់ពីភាពសំបូរបែបនៃសរីរាង្គ នៅក្នុងប្រព័ន្ធបរិស្ថាន និងសង្កេតទំនាក់ទំនងរវាងរុក្ខជាតិ កត្តាចង្រៃ និងពពួកមានប្រយោជន៍ ។

*វាស់ស្ទង់ទិន្នន័យសេដ្ឋកិច្ចពីពិសោធន៍ដូចជា: បាញ់ថ្នាំ ប្រើប្រាស់ជី និងទំលាប់នៃការដាំដុះដំណាំផ្សេងៗ ទៀត ។

*សិក្សាពីឥទ្ធិពលនៃថ្នាំពុលទៅលើសុខភាព និងរៀនកត់សំគាល់នៃរោគសញ្ញាពុលថ្នាំ ។

នៅរៀងរាល់សប្តាហ៍ កសិករសង្ខេបលទ្ធផលនៃការសង្កេតពីស្រែ តាមរយៈការវិភាគប្រព័ន្ធអេកូឡូស៊ីបរិស្ថាន ពិភាក្សាតាមក្រុម និងធ្វើសេចក្តីសំរេចចិត្ត ។ តាមរយៈការធ្វើសេចក្តីសំរេចចិត្តនេះ កសិករត្រូវបានលើកទឹកចិត្តឱ្យចូលរួមពិនិត្យបញ្ហា និងថ្លឹងថ្លែង រួចធ្វើការសំរេចចិត្តដោយខ្លួនឯង ។

ក្រោយពីបញ្ចប់ការសិក្សា IPM កសិករ អាចអភិវឌ្ឍន៍ ការជឿជាក់លើខ្លួនឯង និងអាចកែលំអ ការអនុវត្តន៍ បានកាន់តែល្អប្រសើរ ហើយក្លាយទៅជាអ្នកជំនាញ ក្នុងការដាំដុះដំណាំ ។ សាលារៀនស្រែកសិករ ផ្តល់នូវជំនាញដល់កសិករ ក្នុងការសំរេចចិត្ត ដោយជួយពួកគាត់ឱ្យចេះវិភាគ នូវភាពលូតលាស់នៃដំណាំ ។



សាលារៀន *IPM* លើស្រែកសិករ

## សកម្មភាពតាមដានបន្ត



សកម្មភាពនេះ ជាចំណុចចាប់ផ្តើមមួយយ៉ាងប្រសើរសំរាប់ការអភិវឌ្ឍន៍សហគមន៍ ។ ក្រោមកិច្ចសហប្រតិបត្តិការជាមួយ អង្គការឬភ្នាក់ងារផ្សេងៗ កម្មវិធី IPM បានផ្តល់នូវ សកម្មភាពការងារបន្តជាមួយ និង ក្រុមកសិករដែលបានរៀនចប់នៅសាលារៀនស្រែកសិករ ។ អាស្រ័យទៅតាមកសិករ នៅតាមតំបន់និមួយៗ សកម្មភាពបន្តរួមមាន :

- ការបង្កើតជំនាញក្នុងការគ្រប់គ្រង និងការធ្វើផែនការ ។
- ការចូលរួមសិក្សារបស់កសិករ អំពីប្រព័ន្ធដាំដុះដំណាំដូចជា ការចិញ្ចឹមត្រីក្នុងស្រែ ។
- លើកយក ប្រធានបទបច្ចេកទេសពិសេសមកសិក្សាបន្ថែម បើមានសំណូមពរពីកសិករ ។
- ការដាំដំណាំបន្ទាប់បន្សំ និងដំណាំចំរុះ ។
- ការជ្រើសរើសពូជនិងការគ្រប់គ្រងដីជាតិដី ។
- ការបន្តចូលរួមសកម្មភាពពិសោធន៍ និងស្រាវជ្រាវតាមតំបន់ ។

## ចត្តបណ្តុះបណ្តាលកសិករជាគ្រូបង្ហាត់

នេះជាកិច្ចការថ្មីមួយ ដែលមានសារសំខាន់សំរាប់កម្មវិធីបណ្តុះបណ្តាល សាលារៀនស្រែកសិករ ។ កសិករដែលបានបញ្ចប់ការសិក្សានៅសាលារៀនស្រែកសិករ ក្លាយទៅជាគ្រូបង្រៀន និងផ្សព្វផ្សាយដល់កសិករផ្សេងទៀតអំពី អត្ថប្រយោជន៍នៃការអនុវត្តន៍វិធីសាស្ត្រ IPM ។ សកម្មភាពនេះបានចាប់ផ្តើមដាំដំបូងនៅ ខេត្តព្រៃវែង កណ្តាល តាកែវ កំពង់ស្ពឺ និងស្វាយរៀង ។ កសិករនៅខេត្តផ្សេងៗទៀត នឹងត្រូវបានបញ្ចូលទៅក្នុងកម្មវិធីនេះផងដែរ ។

## ការអភិវឌ្ឍន៍លំហាត់នៅលើវាលស្រែ

ក្រោមកិច្ចសហប្រតិបត្តិការ រវាងគ្រូ IPM និងក្រុមកសិករដែលបានរៀនចប់ កម្មវិធី IPM បានអភិវឌ្ឍន៍នូវលំហាត់ លើវាលស្រែថ្មីៗជាច្រើនសំរាប់ប្រើប្រាស់ក្នុងសកម្មភាពបណ្តុះបណ្តាល IPM ។ លំហាត់ទាំងនេះបានរួមបញ្ចូលបទពិសោធន៍ ដែលមាននៅកម្ពុជា កម្មវិធី IPM នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងលទ្ធផលស្រាវជ្រាវរបស់អង្គការ CIAP ។ លំហាត់នេះ ផ្តោតទៅលើបច្ចេកវិទ្យាថ្មីក្នុងស្រុកដែលឆ្លើយតបទៅនឹង ដំណោះស្រាយបញ្ហាក្នុងតំបន់ ។

## ការពង្រីកបច្ចេកទេសដែលជាអាទិភាពសំរាប់កម្មវិធី IPM នៅកម្ពុជា

កម្មវិធី IPM នៅកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ទៅលើដំណាំស្រូវក្នុងដំណាក់កាលដំបូង ប៉ុន្តែតាមពិត IPM មានទំនាក់ទំនង យ៉ាងសំខាន់ចំពោះដំណាំផ្សេងៗទៀត ។ សកម្មភាពបណ្តុះបណ្តាល IPM បានចាប់ផ្តើមដំណើរការបង្រៀនកសិករដាំបន្លែ ដោយទទួលបានលទ្ធផលល្អ ហើយសង្ឃឹមថាដំណាំផ្សេងទៀត នឹងត្រូវបញ្ចូលក្នុងកម្មវិធីពេលអនាគត ។ ប្រធានបទបច្ចេកទេសជាច្រើន កំពុងត្រូវបានបង្កើនការយកចិត្តទុកដាក់ បញ្ចូលក្នុងកម្មវិធីសិក្សា ។ ប្រធានបទទាំងនេះ រួមមាន :

- ការគ្រប់គ្រងជីជាតិដី និងជីបៃតង
- ការគ្រប់គ្រងស្មៅចង្រៃ
- ការគ្រប់គ្រងជំងឺ
- ការដាំដំណាំបង្វិល និងប្រព័ន្ធកសិកម្ម
- ការរៀបចំដី ឱ្យបានត្រឹមត្រូវ
- ការចិញ្ចឹមបារ៉ាស៊ីតសំរាប់ប្រើប្រាស់ លើដំណាំបន្លែ
- ការសិក្សាពីឥទ្ធិពល នៃថ្នាំពុលកសិកម្មទៅលើជីវចំរុះក្នុងធម្មជាតិ និងសុខភាពមនុស្ស ។















ការចូលរួមរបស់ស្ត្រីក្នុងកម្មវិធី IPM ជាតិនៅកម្ពុជា នារដូវវស្សាឆ្នាំ ១៩៩៦




## ស្ត្រី កុមារ និង IPM

ស្ត្រីដើរតួនាទីយ៉ាងសំខាន់នៅក្នុងការដាំដុះដំណាំ និងការធ្វើសេចក្តីសំរេចចិត្ត ។ កម្មវិធី IPM ជាតិកម្ពុជា បានយកចិត្តទុកដាក់ដល់ក្រុមស្ត្រីនិងបង្កើនការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពការងារ IPM ។ ស្ត្រីយ៉ាងតិច ៣៣% នៃចំនួនសិក្ខាកាមសរុបដែលបានចូលរួមសិក្សានៅ TOT និងFFS ។ ចំនួនកសិករស្ត្រី ដែលចូលរួមក្នុងសកម្មភាពសិក្សា IPM នារដូវវស្សាឆ្នាំ ១៩៩៦ មានបង្ហាញជូនក្នុងក្រាភិច ទី ១ ។ ប្រជាជនកម្ពុជា ជាង ៥០% មានអាយុតិចជាង ១៦ឆ្នាំ ដូចនេះ កុមារមានសក្តានុពលភាព ធំធេងណាស់សំរាប់ទទួលយកនូវផលប្រយោជន៍ពី IPM ។ សាលារៀន IPM បានបើកបង្រៀនសិស្ស អនុវិទ្យាល័យមួយចំនួន ។ សិស្សបានសិក្សាបន្ថែម ដោយអនុវត្តផ្ទាល់នៅលើ មុខវិជ្ជាជាច្រើន ដូចជា : អក្សរសាស្ត្រ បរិស្ថានវិទ្យា គណិតវិទ្យា សេដ្ឋកិច្ច ក្សេត្រសាស្ត្រ ជីវវិទ្យា គំនូរ និងផ្តល់នូវគំនិតរួមគ្នា ក្នុងការអប់រំវិស័យបរិស្ថាន និងសុខាភិបាលផងដែរ ។ នេះគឺជាអាទិភាពមួយ ដែលត្រូវយកចិត្តទុកដាក់ ដើម្បីពង្រីកទំនាក់ទំនងនៃការចូលរួមរបស់ស្ត្រី និងកុមារ ក្នុងសកម្មភាព IPM ឱ្យបានទូលំទូលាយទូទាំងប្រទេស ។





## អង្គការដែលបានផ្តល់ការគាំទ្រ IPM នៅប្រទេសកម្ពុជា

កម្មវិធីអន្តរប្រទេសរបស់អង្គការ FAO សំរាប់ IPM លើដំណាំស្រូវ និងដំណាំបន្លែនៅតំបន់អាស៊ីខាងត្បូង និងអាស៊ីភាគអាគ្នេយ៍ ផ្តល់នូវជំនួយបច្ចេកទេសសំរាប់កម្មវិធី IPM ជាតិកម្ពុជា និងសំរបសំរួលក្នុងការផ្លាស់ប្តូរ បច្ចេកវិទ្យា និងបទពិសោធន៍រវាងកម្ពុជា និងបណ្តាប្រទេសនានានៅទ្វីបអាស៊ី អំពី ការអនុវត្តន៍វិធានការគ្រប់គ្រងកត្តាចង្រៃវិធីសាស្ត្រដាំដុះ និងការបណ្តុះបណ្តាលកសិករ ។ កម្មវិធីការងារនេះបានជួយដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយបានផ្តល់នូវ មន្ត្រីបច្ចេកទេស និងគ្រូបង្គោល IPM ប្រចាំការនៅភ្នំពេញ ដើម្បីអភិវឌ្ឍន៍ IPM នៅកម្ពុជា ។

អង្គការ IRRI-CIAP បានធ្វើការស្រាវជ្រាវ IPM នៅប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ១៩៨៩ និងកំពុងបន្តកម្មវិធីនេះបន្តទៀត ។ IRRI មានបណ្តាញស្រាវជ្រាវជាច្រើនក្នុងតំបន់អាស៊ី ។ ពីឆ្នាំ ១៩៩៦ ដល់ ១៩៩៧ កម្មវិធីសហប្រតិបត្តិការបច្ចេកទេសនៃអង្គការ FAO បានផ្តល់នូវជំនួយថវិកាសំរាប់បណ្តុះបណ្តាល និងពង្រីកការអភិវឌ្ឍន៍ កម្មវិធី IPM ជាតិ ។ អង្គការ IDRC ក៏បានផ្តល់ថវិកាឧបត្ថម្ភសំរាប់ការងារនេះដែរ ។ ក្រៅពីនេះ អង្គការ CARERE សហគមន៍អឺរ៉ុប (PRASAC) UNICEF កម្មវិធីផ្សព្វផ្សាយកម្ពុជា អូស្ត្រាលី (AUSAID) និងអង្គការ NGO ផ្សេងៗទៀត ក៏បានចូលរួមផ្តល់ថវិកាសំរាប់ដំណើរការវគ្គបណ្តុះបណ្តាលដែរ ដែលពង្រាងអោយកម្មវិធី IPM ពង្រីកសកម្មភាពទៅលើខេត្តសំខាន់ៗ ជាច្រើននៅក្នុងប្រទេស ។ នៅឆ្នាំ ១៩៩៧ នេះ កម្មវិធី IPM លើដំណាំបន្លែនៃអង្គការ FAO បានចាប់ផ្តើមដំណើរការនៅប្រទេសកម្ពុជា ។ គំរោងនេះនឹងផ្តល់ការគាំទ្រសំរាប់បណ្តុះបណ្តាលគ្រូ និងបើកសាលារៀនកសិករ នៅលើដំណាំបន្លែ និងប្រព័ន្ធកសិកម្មដំណាំស្រូវ ។



## អនាគត

ដើម្បីសំរេចឱ្យបាននូវគោលដៅនៃកម្មវិធី IPM វាចាំបាច់តំរូវអោយមាន កិច្ចសហការបន្តពីបណ្តាអង្គការនានា ស្ថាប័នរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ភ្នាក់ងារផ្តល់ថវិកាសំរាប់កម្មវិធីអភិវឌ្ឍន៍ និងស្ថាប័នស្រាវជ្រាវនានា ។

នាយកដ្ឋានក្សេត្រសាស្ត្រ កំពុងត្រូវការអ្នកជំនាញសំរាប់រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល IPM និងជួយគ្រូបង្គោល នៅតាមបណ្តាខេត្តនានា ដើម្បីដំណើរការ IPM ។

ទោះបីជាយ៉ាងណាក៏ដោយ ភាពជោគជ័យនៃកម្មវិធី IPM នៅក្នុងទីនេះ គឺអាស្រ័យទៅលើសុឆន្ទៈ ពីបណ្តាអង្គការផ្សេងៗ ក្នុងការចូលរួមវិភាគទាន នូវធនធានមនុស្ស និងហិរញ្ញវត្ថុ និងលើកស្ទួយ IPM នៅតំបន់អភិវឌ្ឍន៍របស់ពួកខ្លួន ។



រូបថតនៅក្នុងឯកសារនេះ តំណាងអោយ អ្នកដឹកនាំ គ្រូបង្គាត់ កសិករ នៃកម្មវិធីIPMនៅក្នុងប្រទេសកម្ពុជា ។

សំរាប់ព័ត៌មានបន្ថែមស្តីពី IPM នៅប្រទេសកម្ពុជា សូមទាក់ទង:
កម្មវិធី IPM ជាតិ
នាយកដ្ឋានក្សេត្រសាស្ត្រ
ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
ភ្នំពេញ
**Tel / Fax** : +855 (023) 364 966

**FAO IPM**
PO Box 53 Phnom Penh
Tel: +855 (023) 426566 , (0) 18 810 242
Fax: +855 (023) 426 547
email: fao-khm@field.fao.org

ឯកសារនេះ បានផលិតឡើងដោយ កម្មវិធី IPM ជាតិ សហការជាមួយកម្មវិធីអន្តរប្រទេសនៃអង្គការ FAO សំរាប់ IPM លើដំណាំស្រូវ និងដំណាំបន្លែ ប្រចាំអាស៊ីភាគខាងត្បូង និងអាស៊ីភាគអគ្នេយ៍។ កម្មវិធីនេះឧបត្ថម្ភដោយ រដ្ឋាភិបាល អូស្ត្រាលី ហុលឡង់ និងស្វីស ។

ការរៀបចំបោះពុម្ព និងក្រាភិចដោយ **DESIGN GROUP**, ភ្នំពេញ
ថតរូបដោយ MARTIN **FLITMAN**, ROBERT **NUGENT**
ភ្នំពេញ ខែធ្នូ ឆ្នាំ ១៩៩៧





# គំនូររបស់ កសិករ





